CAO COMPLIANCE ADVISOR OMBUDSMAN

The Independent Accountability Mechanism for IFC & MIGA

ខែ ធ្នូ ឆ្នាំ ២០២៥

# របាយការណ៍វាយតម្លៃ

## ស្តីពីពាក្យបណ្តឹងទីដប់បីដែលទទួលបាន ពាក់ព័ន្ធនឹងការវិនិយោគរបស់ IFC ក្នុងមូលនិធិបំណុលនៃគំនិតផ្តួចផ្តើមមីក្រូហិរញ្ញវត្ថុសម្រាប់អាស៊ី (MIFA) (គម្រោង IFC លេខ ៣១៤៦៧) និងកម្មសិទ្ធិភាគហ៊ុនក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រឹត (គម្រោង IFC លេខ ៣៤៧៤៨) នៅកម្ពុជា

លេខគម្រោង IFC/MIGA៖ (IFC ៣៤៧៤៨ និង ៣១៤៦៧)

# អំពី CAO

ការិយាល័យទីប្រឹក្សាអនុលោមភាព (ហៅកាត់ថា CAO) គឺជាយន្តការគណនេយ្យភាពឯករាជ្យរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និងទីភ្នាក់ងារធានាការវិនិយោគពហុភាគី (MIGA) ដែលជាសមាជិកនៃក្រុមធនាគារពិភពលោក។ យើងធ្វើការ ដើម្បីសម្របសម្រួលការដោះស្រាយពាក្យបណ្តឹងពីប្រជាជនដែលរងផលប៉ះពាល់ដោយសារគម្រោងរបស់ IFC និង MIGA ប្រកបដោយភាពយុត្តិធម៌ សត្យានុម័ត និងក្នុងលក្ខណៈស្ថាបនា ពង្រឹងលទ្ធផលផ្នែកបរិស្ថាន និងសង្គមរបស់គម្រោង និងជំរុញគណនេយ្យភាពសាធារណៈ និងការសិក្សារៀនសូត្រនៅ IFC និង MIGA។

CAO គឺជាការិយាល័យឯករាជ្យ ដែលរាយការណ៍ដោយផ្ទាល់ទៅក្រុមប្រឹក្សាភិបាលប្រតិបត្តិរបស់ IFC និង MIGA។ សម្រាប់ព័ត៌មានបន្ថែម សូមមើល http://www.cao-ombudsman.org/about-us។

# បញ្ជីពាក្យកាត់

| | | |
|---|---|---|
| Amret | Amret Microfinance Institution PLC | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ភីអិលស៊ី |
| CAO | Office of the Compliance Advisor Ombudsman | ការិយាល័យទីប្រឹក្សាអនុលោមភាព |
| GRM | grievance redress mechanism | យន្តការដោះស្រាយបណ្តឹង |
| IFC | International Finance Corporation | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| LOLC | LOLC Plc | អិលអូអិលស៊ី ភីអិលស៊ី |
| MFI | microfinance institution | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ |
| MIFA | Microfinance Initiative for Asia | គំនិតផ្តួចផ្តើមមីក្រូហិរញ្ញវត្ថុសម្រាប់អាស៊ី |
| MIGA | Multilateral Investment Guarantee Agency | ទីភ្នាក់ងារធានាការវិនិយោគពហុភាគី |
| NBC | National Bank of Cambodia | ធនាគារជាតិនៃកម្ពុជា |

# ១. សង្ខេប

កាលពីខែមិថុនា ឆ្នាំ២០២៥ ការិយាល័យទីប្រឹក្សាអនុលោមភាព (CAO) បានទទួលពាក្យបណ្តឹងមួយពីដើមបណ្តឹងជាបុគ្គលពីររូប ដែលតំណាងដោយអង្គការសម្ព័ន្ធខ្មែរជំរុញ និងការពារសិទ្ធិមនុស្ស ហៅកាត់ថា លីកាដូ ដែលជាអង្គការមិនមែនរដ្ឋាភិបាល ស្តីពីការផ្តល់កម្ចីប្រកបដោយគ្រោះថ្នាក់ នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជា ដែលមានភ្ជាប់ទំនាក់ទំនងទៅនឹងអតិថិជនរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) គឺគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ភីអិលស៊ី ("អម្រឹត") (គម្រោង IFC៖ កម្មសិទ្ធិភាគហ៊ុន MFI អម្រឹត ៣៨៧៤៨) និងអតិថិជនបន្តរបស់ IFC គឺ អិលអូអិលស៊ី ភីអិលស៊ី ("LOLC")។ LOLC គឺជាអតិថិជនបន្តរបស់ IFC តាមរយៈការវិនិយោគរបស់ IFC នៅក្នុងមូលនិធិបំណុលនៃគំនិតផ្តួចផ្តើមមីក្រូហិរញ្ញវត្ថុសម្រាប់អាស៊ី (MIFA) (គម្រោង IFC៖ មូលនិធិបំណុល MIFA ៣១៤៦៧)។ LOLC និង អម្រឹត គឺជាគ្រឹះស្ថានហិរញ្ញវត្ថុពីរក្នុងចំណោមគ្រឹះស្ថានហិរញ្ញវត្ថុចំនួនប្រាំមួយ ដែលកំពុងស្ថិតនៅក្រោមការស៊ើបអង្កេតអនុលោមភាពបន្តដោយ CAO ស្តីពីការអនុវត្តរបស់ធនាគារចំនួនបួន និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួនពីរនៅកម្ពុជា, ហើយ LOLC ក៏ជាប់ពាក់ព័ន្ធក្នុងសំណុំរឿងវិវាទ ដែលកំពុងបន្តដោះស្រាយមួយផ្សេងទៀតរបស់ CAO ផងដែរ។[1]

ដើមបណ្តឹងបានទទួលកម្ចីជាច្រើនពីអម្រឹត និង LOLC នៅចន្លោះឆ្នាំ២០២១ និង ២០២៣។ ពួកគេអះអាងថា កម្ចីទាំងនេះបានបង្កើនភាពលំបាកលំបិនរបស់ពួកគេ ដែលបណ្តាលឱ្យមានការបាត់បង់មុខរបរចិញ្ចឹមជីវិត និងទ្រព្យសម្បត្តិ និងធ្វើឱ្យស្ថានភាពហិរញ្ញវត្ថុរបស់ពួកគេកាន់តែតានតឹងបន្ថែមទៀត។ ពួកគេក៏បានចោទប្រកាន់ផងដែរថា របៀបផ្តល់កម្ចីរបស់អម្រឹត និង LOLC រួមទាំងការគំរាមកំហែងពីមន្ត្រីឥណទាន និងអវត្តមាននៃយន្តការដោះស្រាយបណ្តឹងដ៏មានប្រសិទ្ធភាព បានបង្កគ្រោះថ្នាក់ដល់ពួកគេ និងក្រុមគ្រួសាររបស់ពួកគេ។ នៅខែកក្កដា ឆ្នាំ២០២៥ CAO បានកំណត់ថា ពាក្យបណ្តឹងនេះបានបំពេញតាមលក្ខណៈវិនិច្ឆ័យនៃភាពទទួលយកបាន (eligibility criteria) ទាំងបីរបស់ខ្លួន ហើយបានចាប់ផ្តើមវាយតម្លៃលើពាក្យបណ្តឹងនេះ។

ក្នុងអំឡុងពេលនៃការវាយតម្លៃរបស់ CAO ដើមបណ្តឹង អតិថិជនរបស់ IFC គឺ អម្រឹត និងអតិថិជនបន្តរបស់ IFC គឺ LOLC បានបង្ហាញចំណាប់អារម្មណ៍ចូលរួមក្នុងដំណើរការដោះស្រាយវិវាទរបស់ CAO ដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹងខាងលើ។ នៅខែតុលា ឆ្នាំ២០២៥ ក្នុងអំឡុងពេលបេសកកម្មវាយតម្លៃ ក្រុមការងារ CAO បានកោះប្រជុំរួមលើកដំបូងរវាងដើមបណ្តឹង និង LOLC ហើយភាគីនានាបានព្រមព្រៀងជាគោលការណ៍អំពីរបៀបដោះស្រាយបញ្ហានៅក្នុងពាក្យបណ្តឹង និងបានបញ្ជាក់ពីបំណងជួបប្រជុំគ្នាម្តងទៀតនៅខែធ្នូ ឆ្នាំ២០២៥ ដើម្បីបន្តចូលរួមក្នុងដំណើរការដោះស្រាយវិវាទ ក្រោមការសម្របសម្រួលពី

[1] ព័ត៌មានបន្ថែមអំពីសំណុំរឿងនេះ អាចរកបាននៅ https://www.cao-ombudsman.org/cases/cambodia-financial-intermediaries-04 និង https://www.cao-ombudsman.org/case/cambodia-mef-mifa-debt-fund-04.

CAO។ អនុលោមតាមគោលនយោបាយរបស់ CAO (កថាខណ្ឌ ៥៩ ទំព័រ ១៣)[2] មុខងារដោះស្រាយវិវាទរបស់ CAO នឹងទទួលបន្ទុកចាត់ចែងពាក្យបណ្តឹងនេះបន្តទៅទៀត។

ជាការឆ្លើយតបទៅនឹងសំណើរបស់ដើមបណ្តឹង និងភាពចាំបាច់ក្នុងការដោះស្រាយបញ្ហាហិរញ្ញវត្ថុ និងសង្គមដែលមានលក្ខណៈរសើប ពាក់ព័ន្ធនឹងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗគ្នា ក្រុមការងារដោះស្រាយវិវាទនឹងចាត់ចែងបញ្ហាពាក់ព័ន្ធនឹងអម្រឹត និង LOLC ក្នុងពាក្យបណ្តឹងនេះ ដាក់ដោយឡែកពីគ្នា។ ក្រុមការងារនឹងធានាប្រសិទ្ធភាព ព្រមទាំងសម្របសម្រួលការរៀបចំកិច្ចប្រជុំ ដើម្បីកាត់បន្ថយបន្ទុកលើភាគីនានា និងដើម្បីជៀសវាងធ្វើសកម្មភាពដដែលៗ ក្នុងដំណើរការនេះ។

របាយការណ៍វាយតម្លៃនេះ បង្ហាញជារួមពីដំណើរការវាយតម្លៃ ការពិពណ៌នាអំពីគម្រោង ពាក្យបណ្តឹង វិធីសាស្ត្រវាយតម្លៃ ទស្សនៈរបស់ភាគីនានា និងជំហានបន្ទាប់។

---

[2] សូមមើល គោលនយោបាយ CAO នៅ https://www.cao-ombudsman.org/sites/default/files/documents/CAO%20Policy/ifc-miga-independent-accountability-mechanism-cao-policy.pdf.

# ២. សាវតារ

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អម្រឹត ភីអិលស៊ី** - នៅឆ្នាំ២០១៤ IFC បានអនុម័តការវិនិយោគលើភាគហ៊ុនចំនួន ១៧,៥ លានដុល្លារអាមេរិក សម្រាប់ចំណែកកម្មសិទ្ធិភាគហ៊ុន ១៩,៩៩ ភាគរយ នៅក្នុងអម្រឹត ព្រមទាំងឥណទានធនាគារចំនួន ១០ លានដុល្លារអាមេរិក។(#៣៤៧៤៨)[3] ការវិនិយោគនេះ មានគោលបំណងគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្របរិវត្តកម្ម និងអភិវឌ្ឍន៍រយៈពេលវែងរបស់អម្រឹត។ គម្រោងនេះត្រូវបានចាត់ថ្នាក់ជាប្រភេទ FI-2 ហើយ IFC ជាប់ពាក់ព័ន្ធ តាមរយៈគម្រោងដែលកំពុងអនុវត្តខាងលើនេះ (#៣៤៧៤៨)។

អម្រឹត ដែលជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MFI) ស្ថិតក្នុងចំណោមគ្រឹះស្ថានហិរញ្ញវត្ថុកំពូលទាំង ១០ នៅកម្ពុជា។ គ្រឹះស្ថាននេះត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩១ ដោយអង្គការ GRET របស់បារាំងជាគម្រោងឥណទានជនបទ ដែលដំណើរការតាមរយៈសមាគមភូមិ នៅខេត្តចំនួនបី (កណ្តាល កំពង់ស្ពឺ និងព្រៃវែង)។[4] ក្រុមហ៊ុន Advans បានក្លាយជាម្ចាស់ភាគហ៊ុនភាគច្រើនរបស់អម្រឹត (ដែលមាន ៥២,៧៨ ភាគរយ) នៅក្នុងឆ្នាំ២០១៤–២០១៥ ហើយ IFC បច្ចុប្បន្ន កាន់កាប់ ១៥,៩៩ ភាគរយ នៃភាគហ៊ុនរបស់ Advans។ នៅខែឧសភា ឆ្នាំ២០២៤ ធនាគារ SinoPac ដែលមានមូលដ្ឋាននៅតៃវ៉ាន់ បានទិញយកអម្រឹត ក្នុងតម្លៃប្រមាណ ៥៤៣ លានដុល្លារអាមេរិក។ IFC បានលក់ ៥០ ភាគរយ នៃភាគហ៊ុនរបស់ខ្លួន ដោយកាត់បន្ថយចំណែកកម្មសិទ្ធិភាគហ៊ុនរបស់ខ្លួននៅក្នុង អម្រឹត មកត្រឹម ១០% ហើយ Advans បានលក់ភាគហ៊ុនទាំងអស់របស់ខ្លួន។[5]

**មូលនិធិបំណុលនៃគំនិតផ្តួចផ្តើមមីក្រូហិរញ្ញវត្ថុសម្រាប់អាស៊ី។** មូលនិធិបំណុល MIFA ត្រូវបានផ្តួចផ្តើមឡើងដោយ IFC, KfW និង BlueOrchard Finance ដើម្បីបង្កើនលទ្ធភាពទទួលបានហិរញ្ញវត្ថុសម្រាប់អ្នកខ្ចីខ្នាតតូច និងគ្រួសារដែលមានចំណូលទាប នៅអាស៊ីខាងកើត អាស៊ីខាងត្បូង និងអាស៊ីកណ្តាល (គម្រោង IFC MIFA #៣១៤៦៧)។ យោងតាម IFC មូលនិធិនេះផ្តល់នូវហិរញ្ញប្បទានបំណុលផ្អែកលើទីផ្សារ ដោយផ្តោតជាសំខាន់លើរូបិយប័ណ្ណក្នុងស្រុក និងការផ្តល់ឥណទានរយៈពេលវែង។ មូលនិធិនេះផ្តល់ហិរញ្ញប្បទានដល់អង្គភាពហិរញ្ញវត្ថុ ជាពិសេស គ្រឹះស្ថានហិរញ្ញវត្ថុតូចៗ និងមិនសូវមានការអភិវឌ្ឍ ដែលផ្តល់សេវាដល់សហគ្រាសខ្នាតតូចបំផុត ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFI)។ មូលនិធិនេះរួមចំណែកធ្វើឱ្យមីក្រូហិរញ្ញវត្ថុក្លាយជាប្រភេទទ្រព្យសកម្មមួយ ជាមួយវិនិយោគិនទូទៅ និងរួមចំណែកទាក់ទាញមូលនិធិពីម្ចាស់ជំនួយ សម្រាប់ប្រើប្រាស់ជាមួយនឹងមូលធនឯកជន។ មូលនិធិនេះក៏ជួយកសាងសមត្ថភាពគ្រឹះស្ថានហិរញ្ញវត្ថុ ដែលផ្តល់សេវាដល់សហគ្រាសខ្នាតតូចបំផុតផងដែរ។ មូលនិធិនេះត្រូវបានគ្រប់គ្រងដោយ BlueOrchard Finance ដែលជាអ្នកគ្រប់គ្រងការ

[3] សូមមើល សំណើសុំត្រួតពិនិត្យរបស់ក្រុមប្រឹក្សាគ្រប់គ្រង IFC

[4] សូមមើល https://www.amret.com.kh/en/about-amret

[5] សូមមើល https://www.amret.com.kh/en/blog/amret-sinopac

វិនិយោគមីក្រូហិរញ្ញវត្ថុបែបពាណិជ្ជកម្មឈានមុខគេលំដាប់សកល។ IFC បានអនុម័តការវិនិយោគចំនួន ២០ លានដុល្លារអាមេរិក ក្នុងភាគហ៊ុនអន្តរការី (mezzanine shares) ក្នុងឆ្នាំ២០១២ ដែលតាមរយៈការវិនិយោគនេះ IFC កាន់កាប់ចំណែកភាគហ៊ុន ១០,២៦ ភាគរយ នៅក្នុងមូលនិធិបំណុល MIFA។ ការវិនិយោគនេះត្រូវបានអនុម័តក្នុងឆ្នាំ២០១២ និងចាត់ថ្នាក់ជាប្រភេទ FI ក្រោមគោលនយោបាយចីរភាព កាលពីឆ្នាំ២០០៦ របស់ IFC។

**LOLC -** LOLC បានទទួលកម្ចីចំនួន ១០ លានដុល្លារអាមេរិក ពីមូលនិធិបំណុល MIFA ដែលមានកាលបរិច្ឆេទឥណប្រតិទាន (maturity date) ឆ្នាំ២០២៦ (រូបភាពទី ២)។ នៅខែធ្នូ ឆ្នាំ២០២០ បច្ចុប្បន្នភាពសម្រាប់វិនិយោគិនរបស់មូលនិធិ MIFA បានបង្ហាញថា LOLC ស្ថិតក្នុងចំណោមអតិថិជនធំជាងគេទាំងប្រាំសម្រាប់មូលនិធិនេះ ជាមួយនឹងភាគរយនៃតម្លៃទ្រព្យសកម្មសុទ្ធចំនួន ៣,៩ ភាគរយ។[6] LOLC ពីមុន គឺជាអតិថិជនបន្តរបស់ IFC តាមរយៈកម្មវិធីលើកកម្ពស់មីក្រូហិរញ្ញវត្ថុ (MEF) ប៉ុន្តែ LOLC បានសងផ្តាច់កម្ចីនោះ នៅថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០២៤។

LOLC[7] គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFI) ដែលទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា (NBC) តាំងពីឆ្នាំ ២០០៣ មក។ បង្កើតឡើងដំបូងក្នុងឆ្នាំ១៩៩៤ ជាកម្មវិធីឥណទានដែលគ្រប់គ្រងដោយអង្គការមិនស្វែងរកប្រាក់ចំណេញ Catholic Relief Service គ្រឹះស្ថាននេះត្រូវបានចុះបញ្ជីក្នុងឆ្នាំ២០០២ ក្រោមឈ្មោះ ធនាគារភូមិ (ខេមបូឌា) លីមីតធីត។ ក្នុងឆ្នាំ២០១៥ គ្រឹះស្ថាននេះបានប្តូរឈ្មោះទៅជា អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី។ LOLC គឺជាអតីតអតិថិជនផ្ទាល់របស់ IFC តាមរយៈកម្ចីមួយ ដើម្បីគាំទ្រសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងមធ្យម ក្នុងវិស័យកសិកម្ម (គម្រោង IFC #៣៤៤២២)។ IFC បានដកខ្លួនចេញពីគម្រោងនេះក្នុងឆ្នាំ២០១៧។

---

6 សូមមើល https://www.blueorchard.com/wp-content/uploads/report/mifa/MIFA_InvestorUpdate.pdf

7 សូមមើល https://www.lolc.com.kh/en/an-overview-en

## រូបភាពទី ១. ទំនាក់ទំនងផ្នែកហិរញ្ញវត្ថុរបស់ IFC ជាមួយអម្រឹត




## រូបភាពទី ២. ទំនាក់ទំនងផ្នែកហិរញ្ញវត្ថុរបស់ IFC ជាមួយ LOLC



# ៣. គោលបំណង និងវិធីសាស្ត្រនៃការវាយតម្លៃ

## គោលបំណងនៃការវាយតម្លៃ

ដំណើរការវាយតម្លៃរបស់ CAO មានគោលបំណងស្វែងយល់ឱ្យបានស៊ីជម្រៅអំពីបញ្ហា និងកង្វល់ដែលបានលើកឡើងដោយដើមបណ្តឹង, ប្រមូលព័ត៌មានស្តីពីទស្សនៈរបស់ភាគីពាក់ព័ន្ធនានា, និងកំណត់ថាតើដើមបណ្តឹង និងអតិថិជនរបស់ IFC ចង់បន្តដំណើរការដោះស្រាយវិវាទ ក្រោមការសម្របសម្រួលដោយ CAO ឬថាតើពាក្យបណ្តឹងគួរតែត្រូវបានទទួលបន្ទុកដោយមុខងារអនុលោមភាពរបស់ CAO ដែលនឹងមានការវាយតម្លៃ ធៀបនឹងស្តង់ដារសមិទ្ធកម្មរបស់ IFC។ (សូមមើលឧបសម្ព័ន្ធ A សម្រាប់ការពិពណ៌នាអំពីដំណើរការដោះស្រាយពាក្យបណ្តឹងរបស់ CAO។)

ដំណើរការវាយតម្លៃរបស់ CAO មិនធ្វើការវិនិច្ឆ័យលើអង្គហេតុនៃពាក្យបណ្តឹងឡើយ។ គោលដៅនៃដំណើរការនេះ គឺដើម្បីស្វែងយល់ពីទស្សនៈរបស់ភាគីនានា និងជួយឱ្យអ្នកពាក់ព័ន្ធធ្វើការសម្រេចចិត្តផ្អែកលើព័ត៌មានត្រឹមត្រូវ អំពីរបៀបដោះស្រាយបញ្ហាដែលបានលើកឡើង។

## វិធីសាស្ត្រវាយតម្លៃ

រូបភាពទី ៣ បង្ហាញពីអភិក្រម និងវិធីសាស្ត្រ ដែលត្រូវបានអនុវត្តនៅក្នុងដំណើរការវាយតម្លៃរបស់ CAO។

**រូបភាពទី ៣. ដំណើរការវាយតម្លៃរបស់ CAO**

តាមរយៈដំណើរការវាយតម្លៃ, CAO មានគោលបំណងស្វែងយល់ឱ្យបានច្បាស់លាស់បន្ថែមទៀត អំពីបញ្ហានានានៅក្នុងពាក្យបណ្តឹង និងកំណត់ថាតើភាគីនានាមានបំណងដោះស្រាយពាក្យបណ្តឹង តាមរយៈដំណើរការដោះស្រាយវិវាទ ឬដំណើរការអនុលោមភាព។ ការវាយតម្លៃនេះ រួមមាន៖

- ការពិនិត្យលើឯកសារគម្រោងរបស់ IFC និងឯកសារពាក់ព័ន្ធផ្សេងទៀត
- កិច្ចប្រជុំតាមប្រព័ន្ធអនឡាញ និងដោយផ្ទាល់ ជាមួយក្រុមការងារគម្រោង IFC និងក្រុមការងារទទួលបន្ទុកការចូលរួមរបស់ភាគីពាក់ព័ន្ធ និងការដោះស្រាយបណ្តឹង របស់ IFC
- កិច្ចប្រជុំតាមប្រព័ន្ធអនឡាញ និងដោយផ្ទាល់ ជាមួយអម្រឹត និង LOLC
- កិច្ចប្រជុំជាមួយដើមបណ្តឹង និងតំណាងអង្គការមិនមែនរដ្ឋាភិបាលរបស់ពួកគេ គឺ អង្គការសម្ព័ន្ធខ្មែរជំរុញ និងការពារសិទ្ធិមនុស្ស
- ដំណើរទស្សនកិច្ចវាយតម្លៃមកកាន់ប្រទេសកម្ពុជា

**របាយការណ៍វាយតម្លៃ**

**លទ្ធផល៖** ដើមបណ្តឹង និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFI) សម្រេចចិត្តផ្តើមដំណើរការដោះស្រាយវិវាទ

**ការដោះស្រាយវិវាទ**

ការវាយតម្លៃនេះ ត្រូវបានធ្វើឡើងដោយក្រុមការងារវាយតម្លៃរបស់ CAO ដោយមានការគាំទ្រពីអ្នកបកប្រែភាសាក្នុងស្រុកម្នាក់ដែលមានមូលដ្ឋាននៅកម្ពុជា ដែលបានជួយក្នុងការបកប្រែភាសាខ្មែរលើឯកសារ និងផ្ទាល់មាត់។ ក្រុមការងារ CAO និងអ្នកបកប្រែភាសា បានទំនាក់ទំនងជាមួយភាគីនានា និងបានប្រមូលព័ត៌មានតាមរយៈការសន្ទនាស៊ីជម្រៅ ទាំងតាមប្រព័ន្ធអនឡាញ និងដោយផ្ទាល់ ព្រមទាំងតាមរយៈការចុះដល់កន្លែង ចាប់ពីថ្ងៃទី២៥ ខែកញ្ញា ដល់ថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៥។

# ៤. ទស្សនៈរបស់ដើមបណ្តឹង

ដើមបណ្តឹងបានទទួលកម្ចីជាច្រើនពី អម្រឹត និង LOLC នៅចន្លោះឆ្នាំ២០២១ និង ២០២៣ ដែលពួកគេអះអាងថា បានបង្កឱ្យពួកគេជួបការលំបាកលំបិនយ៉ាងខ្លាំង រួមមាន ការបាត់បង់មុខរបរចិញ្ចឹមជីវិត ផលប៉ះពាល់អវិជ្ជមានលើការអប់រំរបស់កូនៗរបស់ពួកគេ និងបន្ទុកហិរញ្ញវត្ថុបន្ថែម។ ដើមបណ្តឹងអះអាងថា ពួកគេបានរងគ្រោះថ្នាក់ដោយសាររបៀបផ្តល់កម្ចីប្រកបដោយគ្រោះថ្នាក់របស់អម្រឹត និង LOLC រួមទាំងការជួបប្រទះការគំរាមកំហែង និងការបំភិតបំភ័យពីមន្ត្រីឥណទាន នៅពេលដែលពួកគេមិនអាចសងប្រាក់កម្ចី និងការតម្រូវឱ្យឆ្លងកាត់យន្តការដោះស្រាយបណ្តឹង (GRM) ដែលគ្មានប្រសិទ្ធភាព ដើម្បីដោះស្រាយកង្វល់របស់ពួកគេ។ បញ្ហាដែលបានលើកឡើងដោយដើមបណ្តឹងនៅក្នុងពាក្យបណ្តឹងរបស់ពួកគេ និងបានរៀបរាប់ដោយផ្ទាល់ប្រាប់ទៅក្រុមការងារវាយតម្លៃរបស់ CAO ត្រូវបានពន្យល់ដូចខាងក្រោម។

### ការថយចុះប្រាក់ចំណូល និងការកើនឡើងបំណុល

ដើមបណ្តឹងបានរាយការណ៍ថា ពួកគេបានទទួលកម្ចីពី អម្រឹត និង LOLC ដើម្បីទិញដី និងពូជស្រូវ សម្រាប់ធ្វើស្រែប្រាំង។ ទោះជាយ៉ាងណា ដោយសារទឹកជំនន់ធ្ងន់ធ្ងរដែលបានបំផ្លាញដំណាំរបស់ពួកគេ ពួកគេបានទទួលរងការខាតបង់យ៉ាងធ្ងន់ធ្ងរ និងមិនអាចបំពេញកាតព្វកិច្ចសងប្រាក់កម្ចីបានឡើយ។ ពួកគេអះអាងថា ការដាក់សម្ពាធពីមន្ត្រីឥណទានឱ្យសងប្រាក់កម្ចីទាំងនេះ រួមទាំងការគំរាមកំហែង និងការបំភិតបំភ័យ បានបង្ខំឱ្យពួកគេស្វែងរកឥណទានបន្ថែមពីអ្នកផ្តល់កម្ចីក្រៅផ្លូវការ ដែលធ្វើឱ្យបំណុលសរុបរបស់ពួកគេកើនឡើងយ៉ាងខ្លាំង។ ដើមបណ្តឹងបានអះអាងបន្ថែមថា មន្ត្រីឥណទានបានដាក់សម្ពាធឱ្យពួកគេលក់ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ដើម្បីសងបំណុលដែលនៅសល់។

*ដើមបណ្តឹងទី១* បាននិយាយថា គាត់មានលទ្ធភាពបង់ការប្រាក់ជាទៀងទាត់ ក្នុងអំឡុងឆ្នាំដំបូងនៃកម្ចី ប៉ុន្តែខ្វះធនធាន ដើម្បីសងប្រាក់ដើម។ គាត់បានអះអាងថា មន្ត្រីឥណទានបានទៅផ្ទះរបស់គាត់ រៀបចំឥណទានឡើងវិញ និងបានតម្រូវឱ្យគាត់ចាប់ផ្តើមសងទាំងប្រាក់ដើម និងការប្រាក់។ ដើមបណ្តឹងបាននិយាយថា ក្នុងអំឡុងពេលដំណើរការរៀបចំឥណទានឡើងវិញ គាត់ខ្វះប្រាក់ ៥ ដុល្លារអាមេរិក ហើយជាការឆ្លើយតប មន្ត្រីឥណទានបាន

ណែនាំឱ្យគាត់យកទូរស័ព្ទទៅបញ្ចាំ ឬសុំលុយពីសាច់ញាតិ ដើម្បីបំពេញលុយដែលខ្វះនេះ និងបានសាកសួរថាតើគាត់មានទ្រព្យសម្បត្តិអ្វីនៅផ្ទះដែលអាចលក់បានដែរឬទេ។ ដើមបណ្ដឹងបាននិយាយថា គាត់បានព្យាយាមបំពេញកាតព្វកិច្ច ក្រោមសម្ពាធនេះអស់រយៈពេលជាច្រើនខែ ប៉ុន្តែនៅទីបំផុត គាត់លែងមានលទ្ធភាពសងបានទៀត។ គាត់បានពន្យល់ថា គាត់បានលក់ទ្រព្យសកម្មដែលប្រើប្រាស់សម្រាប់បង្កើតប្រាក់ចំណូលជាច្រើន ដើម្បីបំពេញតាមការតម្រូវការឱ្យសងប្រាក់ ដូចជា ម៉ាស៊ីនបូមទឹក ឧបករណ៍បាញ់ថ្នាំសម្លាប់សត្វល្អិត និងឧបករណ៍កសិកម្មសំខាន់ៗផ្សេងទៀត ដែលចាំបាច់សម្រាប់ការដាំដុះស្រូវប្រាំង។

*ដើមបណ្ដឹងទី២* បានរាយការណ៍ថា គាត់បានខ្ចីប្រាក់ពីអ្នកផ្ដល់កម្ចីក្រៅផ្លូវការ ដើម្បីទូទាត់បំណុលរបស់គាត់ ដោយសារតែគាត់មិនមានថវិកាគ្រប់គ្រាន់ ដើម្បីបំពេញកាតព្វកិច្ចសងកម្ចីរបស់គាត់ជាមួយ LOLC និង អម្រឹត។ គាត់បាននិយាយថា គាត់បានលក់ម៉ូតូ គោយន្ត និងឧបករណ៍កសិកម្មផ្សេងៗ ដើម្បីសងប្រាក់ទៅអ្នកផ្ដល់កម្ចីក្រៅផ្លូវការ ហើយថា នៅទីបំផុត គាត់ត្រូវលក់ដីរបស់គាត់ ដើម្បីសងកម្ចីរបស់ អម្រឹត។

ដើមបណ្ដឹងទាំងពីរបានអះអាងថា ការលក់ឧបករណ៍កសិកម្មសំខាន់ៗ និងដីធ្លី — ដែលជាប្រភពសំខាន់ៗសម្រាប់រកប្រាក់ចំណូល — បានប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេ បានកាត់បន្ថយសមត្ថភាពរបស់ពួកគេក្នុងការបន្តធ្វើកសិកម្មបង្កបង្កើនផល និងបានធ្វើឱ្យភាពងាយរងគ្រោះផ្នែកហិរញ្ញវត្ថុរបស់ពួកគេកាន់តែធ្ងន់ធ្ងរទៅៗ។

## ផលប៉ះពាល់អវិជ្ជមានលើគ្រួសារ សុខភាព និងការអប់រំរបស់កុមារ

*ដើមបណ្ដឹងទី១* បាននិយាយថា មន្ត្រីឥណទានម្នាក់បានទៅផ្ទះរបស់គាត់ ខណៈពេលដែលគាត់មិននៅ ហើយបានប្រាប់កូនៗរបស់គាត់អំពីបំណុលមិនទាន់ទូទាត់។ គាត់បានអះអាងថា ក្រោយមកកូនៗរបស់គាត់បានប្រាប់គាត់ថា ពួកគេមិនអាចផ្ដោតអារម្មណ៍លើការសិក្សាបានទេ ដោយសារតែភាពតានតឹងដែលបណ្ដាលមកពីស្ថានភាពហិរញ្ញវត្ថុរបស់គ្រួសារ ហើយនៅទីបំផុត ក៏បានបោះបង់ការសិក្សា ដើម្បីទៅរកចំណូលជួយឪពុកម្ដាយសងប្រាក់កម្ចី។ ដើមបណ្ដឹងបានបង្ហាញពីកង្វល់យ៉ាងខ្លាំងថា កូនៗរបស់គាត់បច្ចុប្បន្នកំពុងធ្វើការក្រោមស្ថានភាពដ៏លំបាក និងបាត់បង់ឱកាសទទួលបានការអប់រំរបស់ពួកគេ។

*ដើមបណ្ដឹងទី២* បានអះអាងថា ប្ដីរបស់គាត់បានពុលថ្នាំសម្លាប់សត្វល្អិត ខណៈពេលកំពុងបាញ់ថ្នាំក្នុងអំឡុងពេលធ្វើស្រែប្រាំង។ គាត់ជឿថា ជំងឺរបស់ប្ដីគាត់គឺទាក់ទងនឹងកម្ចីពី LOLC ពីព្រោះប្ដីគាត់ត្រូវប្រឹងប្រែងធ្វើការលើសពីធម្មតាក្នុងអំឡុងពេលបាញ់ថ្នាំសម្លាប់សត្វល្អិត ដើម្បីបំពេញកាតព្វកិច្ចសងប្រាក់។ ដើមបណ្ដឹងបាននិយាយថា គាត់បានប្រាប់មន្ត្រីឥណទានថា គាត់មិនអាចធ្វើការបានទេ ដោយសារគាត់មានផ្ទៃពោះ ហើយប្ដីរបស់គាត់ក៏មានសុខភាពមិនល្អ ហើយជាការឆ្លើយតប មន្ត្រីឥណទានបានណែនាំឱ្យកូនៗរបស់គាត់ទៅធ្វើការងារតាមរដូវ ដូចជា ស៊ីឈ្នួលបេះចន្ទី ប៉ុន្តែគាត់បានបដិសេធ។

## ការគំរាមកំហែង និងការបំភិតបំភ័យ

ដើមបណ្តឹងទាំងពីរបានអះអាងថា មន្ត្រីឥណទានបានទៅផ្ទះរបស់ពួកគេជារៀងរាល់ខែ និងបានគំរាមរាយការណ៍ពួកគេទៅមេភូមិ និងបន្តចំណាត់ការផ្លូវច្បាប់ ប្រសិនបើពួកគេមិនបង់ប្រាក់កម្ចី។ ដើមបណ្តឹងទាំងពីរបាននិយាយថា ពួកគេបានពន្យល់ទៅ អម្រឹត និង LOLC ថា ពួកគេមិនយល់អំពីនីតិវិធីច្បាប់ទេ ហើយពួកគេបានបន្តប្រាប់មន្ត្រីឥណទានជាច្រើនលើក ដើម្បីបញ្ជាក់ថា ពួកគេពុំមានលទ្ធភាពសងប្រាក់កម្ចីរបស់ពួកគេបានទេ ដោយសារមូលហេតុនានា ដូចជា ជំងឺរបស់ប្តី និងភាពចាំបាច់ក្នុងការមើលថែទាំកូនតូចៗ។ ដើមបណ្តឹងទាំងពីរបានចោទប្រកាន់ថា មន្ត្រីឥណទានរបស់អម្រឹត និង LOLC បានគំរាមកំហែងពួកគេ ដោយនិយាយថា ប្រសិនបើពួកគេមិនមានលទ្ធភាពសងបំណុលបានទេ កូនៗ និងកូនចៅជំនាន់ក្រោយរបស់ពួកគេ នឹងត្រូវទទួលខុសត្រូវចំពោះបំណុលរបស់ពួកគេ។ ដើមបណ្តឹងបាននិយាយថា ពួកគេមិនចង់ឱ្យកូនៗរបស់ពួកគេទ្រាំទ្របន្ទុកនេះទេ ដូច្នេះហើយទើបបានយល់ព្រមលើកិច្ចព្រមព្រៀងរៀបចំឥណទានឡើងវិញចុងក្រោយ ជាមួយនឹងលក្ខខណ្ឌដែលពុំផ្តល់ភាពអនុគ្រោះដល់ពួកគេ។

នៅពេលដាក់ពាក្យបណ្តឹងទៅ CAO ដើមបណ្តឹងបានស្នើសុំឱ្យរក្សាព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេជាការសម្ងាត់ ដោយសារតែការភ័យខ្លាចចំពោះការគំរាមកំហែង និងការបំភិតបំភ័យ។ ទោះជាយ៉ាងណា ពួកគេបានយល់ព្រមបង្ហាញព័ត៌មានរបស់ពួកគេ និងព័ត៌មានលម្អិតនៃពាក្យបណ្តឹងទៅអម្រឹត និង LOLC ក្នុងអំឡុងពេលដំណើរទស្សនកិច្ចវាយតម្លៃរបស់ CAO ពីខែកញ្ញា ដល់ខែតុលា ឆ្នាំ២០២៥។

## កង្វះយន្តការដោះស្រាយបណ្តឹង (GRM) ដ៏មានប្រសិទ្ធភាព

ដើមបណ្តឹងបានរាយការណ៍ថា ពួកគេបានទៅរកយន្តការដោះស្រាយបណ្តឹង (GRM) ថ្នាក់ឃុំ និងធនាគារជាតិនៃកម្ពុជា (NBC) ដែលជានិយតករទទួលខុសត្រូវដោះស្រាយបណ្តឹងរបស់អ្នកខ្ចី ជាច្រើនលើក ដើម្បីស្នើសុំការលុបចោលកម្ចី ដោយសារតែពួកគេពុំមានលទ្ធភាពសងប្រាក់ ប៉ុន្តែមិនបានជោគជ័យ។ ពួកគេក៏បានដាក់ពាក្យបណ្តឹងតាមរយៈប្រព័ន្ធដោះស្រាយបណ្តឹងអនឡាញ របស់ធនាគារជាតិនៃកម្ពុជាផងដែរ ប៉ុន្តែមិនអាចឈានដល់ដំណោះស្រាយបានទេ។

យោងតាមដើមបណ្តឹងម្នាក់ក្នុងចំណោមដើមបណ្តឹងទាំងពីរ LOLC បានរៀបចំឥណទានរបស់គាត់ឡើងវិញ បានកាត់បន្ថយអត្រាការប្រាក់ និងបានអនុញ្ញាតឱ្យគាត់បង់ត្រឹមតែការប្រាក់សម្រាប់រយៈពេលប្រាំមួយខែ។ ក្រោយមក គាត់បានស្នើសុំការលើកលែងការប្រាក់ទាំងស្រុង និងបានស្នើធ្វើការទូទាត់ចំនួន ២៥ ដុល្លារក្នុងមួយឆ្នាំ — ឬបង់សង តាមអ្វីដែលគាត់អាចធ្វើបាន ផ្អែកលើប្រាក់ចំណូលរបស់គាត់ ប៉ុន្តែសំណើនេះត្រូវបានបដិសេធដោយការិយាល័យ LOLC ខេត្តកំពង់ធំ។ គាត់បានទាក់ទងទៅ NBC ប៉ុន្តែមិនបានទទួលដំណោះស្រាយអ្វីឡើយ។

នៅចន្លោះខែមេសា និងឧសភា ឆ្នាំ២០២៣ ដើមបណ្ដឹងបានដាក់ពាក្យបណ្ដឹងផ្លូវការទៅធនាគារជាតិនៃកម្ពុជា ប៉ុន្តែ យោងតាមដើមបណ្ដឹងទាំងពីរ ធនាគារជាតិនៃកម្ពុជាបានបដិសេធមិនទទួលយកពាក្យបណ្ដឹងពីដើមបណ្ដឹងម្នាក់ ក្នុងចំណោមដើមបណ្ដឹងទាំងពីរនាក់ ដោយបញ្ជាក់ថា បណ្ដឹងទាំងពីរគឺដូចគ្នាបេះបិទ ហើយបន្តចាត់ការតែបណ្ដឹងដែលបានដាក់ដោយដើមបណ្ដឹងទីពីរប៉ុណ្ណោះ ដោយចំណាត់ការនេះមិននាំឱ្យស្ថានភាពរបស់ពួកគេបានប្រសើរជាដុំកំភួននោះទេ។ ដើមបណ្ដឹងដែលបណ្ដឹងរបស់គាត់ត្រូវបានទទួលយក បាននិយាយថា ធនាគារជាតិនៃកម្ពុជាបានជូនដំណឹងដល់គាត់ថា ពួកគេនឹងបញ្ជូនក្ដីកង្វល់របស់គាត់ទៅ LOLC និងរៀបចំការប្រជុំរវាងភាគីទាំងពីរ។ កិច្ចប្រជុំមួយត្រូវបានកំណត់ពេល ប៉ុន្តែគាត់មិនអាចចូលរួមបានទេ ដោយសារគាត់មានផ្ទៃពោះ ហើយពាក្យបណ្ដឹងរបស់គាត់កំពុងស្ថិតក្នុងដំណើរការរបស់ CAO រួចហើយ។

## ៥. ទស្សនៈរបស់អតិថិជន និងអតិថិជនបន្តរបស់ IFC/MIGA

ក្នុងអំឡុងដំណាក់កាលវាយតម្លៃ CAO បានចូលរួមពិភាក្សាជាមួយតំណាងពី អម្រឹត និង LOLC។ ភាគីទាំងអស់ រួមទាំងអ្នកគ្រប់គ្រងមូលនិធិរបស់ MIFA បានបង្ហាញពីការបន្តគាំទ្ររបស់ពួកគេ ដល់ដំណើរការរបស់ CAO។

### ទស្សនៈរបស់អម្រឹត

តំណាងអម្រឹត បានទទួលស្គាល់ថា ការជាប់បំណុលវ័ណ្ឌក គឺជាបញ្ហាជាប្រព័ន្ធ នៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ហើយបានបញ្ជាក់ពីការប្ដេជ្ញាចិត្តរបស់ពួកគេក្នុងការដោះស្រាយបញ្ហានេះ។ ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេ ក្រុមប្រឹក្សាភិបាល និងម្ចាស់ភាគហ៊ុនរបស់ អម្រឹត បានបង្កើតគណៈកម្មាធិការការពារអតិថិជន ដែលទទួលបន្ទុករៀបចំ និងអនុវត្តវិធានការនានា ដើម្បីកាត់បន្ថយបញ្ហាជាប់បំណុលវ័ណ្ឌករបស់អ្នកខ្ចី រួមទាំងផ្ដល់ការបណ្ដុះបណ្ដាលដល់អតិថិជនរបស់ពួកគេ និងពិនិត្យឡើងវិញនូវគោលការណ៍ណែនាំស្ដីពីការផ្ដល់កម្ចីរបស់ពួកគេ ដើម្បីជំរុញការអនុវត្តការផ្ដល់កម្ចីឱ្យកាន់តែមាននិរន្តរភាព។ ឆ្លើយតបទៅនឹងកង្វល់ដែលបានលើកឡើងនៅក្នុងពាក្យបណ្ដឹង អម្រឹតបានផ្ដល់ព័ត៌មានខាងក្រោមទាក់ទងនឹងគោលនយោបាយ និងដំណើរការផ្ទៃក្នុងរបស់ខ្លួន។

### *ការរៀបចំឥណទានឡើងវិញ*

អម្រឹត បានបញ្ជាក់ថា ប្រហែល ១០ ភាគរយ នៃផលប័ត្រឥណទាន (portfolio) របស់ខ្លួន រួមមានកម្ចីដែលបានរៀបចំរចនាសម្ព័ន្ធឡើងវិញ ដែលអនុវត្តស្របតាមគោលការណ៍ណែនាំរបស់ NBC។ អម្រឹត បានកត់សម្គាល់ថា ខ្លួនក៏ផ្ដល់ជូនការរៀបចំឥណទានឡើងវិញ ដើម្បីឆ្លើយតបទៅនឹងផលវិបាកសេដ្ឋកិច្ចដែលកើតឡើងជាទូទៅ ដូចជាការរាតត្បាតជំងឺកូវីដ-១៩ និងជម្លោះកម្ពុជា-ថៃ ឆ្នាំ២០២៥ ជាដើម។ អម្រឹត បានបញ្ជាក់ផងដែរថា គោលនយោបាយរៀបចំឥណទានឡើងវិញថ្មីមួយ ត្រូវបានដាក់ឱ្យអនុវត្ត ចាប់ពីឆ្នាំ២០២៣។ តាមការលើកឡើងរបស់

អម្រឹត ដោយសារគោលនយោបាយនេះមិនទាន់ត្រូវបានអនុវត្តនៅឡើយ នៅពេលដែលដើមបណ្តឹងស្នើសុំការរៀបចំឥណទានឡើងវិញ គោលនយោបាយនេះមិនអាចអនុវត្តចំពោះករណីរបស់ពួកគេបានទេ។ ទោះជាយ៉ាងណា កម្ចីរបស់ដើមបណ្តឹងម្នាក់ ត្រូវបានរៀបចំឡើងវិញនៅខែឧសភា ឆ្នាំ២០២៣ បន្ទាប់ពីការដាក់ពាក្យបណ្តឹងរបស់គាត់។ អម្រឹត បានបញ្ជាក់ថា គាត់បានធ្វើការទូទាត់ជាទៀងទាត់ពីខែមិថុនា ដល់ខែតុលា ឆ្នាំ២០២៣ ប៉ុន្តែក្រោយមក បានស្នើសុំកម្ចីបន្ថែមចំនួន ៤,០០០ ដុល្លារអាមេរិក ដែលត្រូវបានបដិសេធដោយអម្រឹត ដោយផ្អែកលើការវាយតម្លៃលទ្ធភាពសងប្រាក់របស់គាត់។ តាមការលើកឡើងរបស់អម្រឹត បន្ទាប់ពីការបដិសេធ ដើមបណ្តឹងបានឈប់ធ្វើការទូទាត់ និងបានដាក់សំណើទៅធនាគារជាតិនៃកម្ពុជា ក្នុងខែមេសា ឆ្នាំ២០២៤ ដើម្បីសុំលុបចោលបំណុល ដែលក៏ត្រូវបានបដិសេធផងដែរ។

### *ការវាយតម្លៃកម្ចី និងទ្រព្យធានា*

អម្រឹត បានបញ្ជាក់ថា ប្រវត្តិដំណើរការផ្តល់កម្ចីរបស់ពួកគេ រួមមាន ការវាយតម្លៃបញ្ជាក់ពីភាពត្រឹមត្រូវ (due diligence) ដើម្បីធានាថាកម្ចីស្របតាមសមត្ថភាពសងប្រាក់របស់អ្នកខ្ចី។ ដើមបណ្តឹងម្នាក់ក្នុងចំណោមដើមបណ្តឹងទាំងពីរ បានទទួលកម្ចីជាក្រុម ដែលមិនតម្រូវឱ្យមានទ្រព្យធានា ពីព្រោះកម្ចីប្រភេទនេះ ត្រូវបានរៀបចំឡើងដោយគ្មានការធានា។ ដើមបណ្តឹងទីពីរ គឺជាអតិថិជនរបស់អម្រឹត អស់រយៈពេលប្រាំពីរឆ្នាំ ដោយមានកំណត់ត្រាសងប្រាក់យ៉ាងល្អ។ អម្រឹត បានអះអាងថា គាត់បានបង្កើនការខ្ចីប្រាក់របស់គាត់ជាបណ្តើរៗ ហើយថ្មីៗនេះ បានទទួលកម្ចីសម្រាប់ធ្វើកសិកម្ម ជាពិសេសសម្រាប់ការដាំដុះលើដីស្រែចំនួន ២០ ហិកតា ហើយថាកម្ចីរបស់គាត់ត្រូវបានផ្តល់ជូន ផ្អែកលើកម្មសិទ្ធិដីធ្លី និងប្រវត្តិសងប្រាក់របស់គាត់ នៅពេលដាក់ពាក្យស្នើសុំ។ យោងតាមអម្រឹត ប្រាក់ចំណូលរបស់គាត់បានធ្លាក់ចុះ បន្ទាប់ពីរដ្ឋាភិបាលបានហាមឃាត់ការធ្វើកសិកម្មនៅតំបន់មួយចំនួនដែលនៅជាប់នឹងទន្លេ ដែលបានប៉ះពាល់ដល់លទ្ធភាពសងប្រាក់របស់គាត់។

អម្រឹត បាននិយាយថា ខ្លួនកាន់កាប់ប័ណ្ណកម្មសិទ្ធិប្លង់ទន់សម្រាប់ដីរបស់អ្នកខ្ចី ជាឧបករណ៍ធានា ដែលមិនរារាំងដល់លទ្ធភាពរបស់អ្នកខ្ចីក្នុងការរកចំណូលពីអចលនទ្រព្យនោះទេ។ អម្រឹត បានបង្ហាញពីកង្វល់ថា ប្រសិនបើប័ណ្ណកម្មសិទ្ធិដីធ្លីត្រូវបានប្រគល់ជូនវិញ វានឹងមានហានិភ័យខ្ពស់ដែលអ្នកខ្ចីនឹងលក់ទ្រព្យសកម្មនោះ ដើម្បីសងបំណុលទៅឱ្យអ្នកផ្តល់កម្ចីផ្សេងទៀត។ អម្រឹត បានអះអាងថា នេះនឹងបណ្តាលឱ្យមានការបាត់បង់ទ្រព្យសកម្ម ប្រើប្រាស់សម្រាប់ផលិតកម្មជាចម្បងរបស់ពួកគេ ហើយអាចធ្វើឱ្យគ្រឹះស្ថានដែលបានជួយសម្រួលដល់ការលក់នោះ ប្រឈមនឹងការចោទប្រកាន់ថា បានធ្វើឱ្យអ្នកខ្ចីបាត់បង់ទ្រព្យសកម្មទៅវិញ។ លើសពីនេះទៀត អម្រឹត បានកត់សម្គាល់ថា សំណើសុំបញ្ចេញទ្រព្យធានាទៅឱ្យអ្នកខ្ចី ហាក់ដូចជាផ្ទុយនឹងគោលដៅរបស់វិស័យ ក្នុងការទប់ស្កាត់បញ្ហាបំណុលវ័ណ្ឌក។ តាមការលើកឡើងរបស់អម្រឹត ប្រសិនបើប័ណ្ណកម្មសិទ្ធិដីធ្លីត្រូវបានផ្តល់ទៅឱ្យអ្នកខ្ចីវិញ វាអាចត្រូវបានប្រើប្រាស់ជាទ្រព្យធានាសម្រាប់កម្ចីថ្មីពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFI) ផ្សេងទៀត ដែលអាចធ្វើឱ្យបន្ទុកបំណុលរបស់អតិថិជនកាន់តែធុនធ្ងរ ជាជាងការសម្រាលបន្ទុកនេះ។

### *បណ្តឹងរបស់អ្នកខ្ចី និងយន្តការដោះស្រាយបណ្តឹង*

អម្រឹត បានអះអាងថា យន្តការដោះស្រាយបណ្តឹង (GRM) របស់ពួកគេដំណើរការល្អ ហើយថាឥណទានត្រូវបានរៀបចំឡើងវិញ នៅពេលដែលដើមបណ្តឹងបានធ្វើការស្នើសុំនៅការិយាល័យអម្រឹត។ អម្រឹត បាននិយាយថា ខ្លួនរៀបចំនូវច្រកជាច្រើនសម្រាប់អ្នកខ្ចីដាក់ពាក្យបណ្តឹង ដូចជា នៅការិយាល័យសាខា និងការិយាល័យកណ្តាល ជាដើម។ អ្នកខ្ចីត្រូវបានលើកទឹកចិត្តឱ្យបញ្ជូនបន្តកង្វល់របស់ពួកគេទៅស្ថាប័នខាងក្រៅ ដូចជា ធនាគារជាតិនៃកម្ពុជា និងមជ្ឈមណ្ឌលការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ ដែលទើបបង្កើតថ្មី ជាដើម។

### *ការគំរាមកំហែង និងការបំភិតបំភ័យ*

អម្រឹត បានពន្យល់ដល់ CAO ថា ក្នុងរយៈពេលបីឆ្នាំកន្លងមកនេះ ខ្លួនបានផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីឥណទានរបស់ខ្លួន អំពីរបៀបប្រមូលបំណុលប្រកបដោយការទទួលខុសត្រូវ ដោយផ្តោតលើការលុបបំបាត់ការគំរាមកំហែង និងការបំភិតបំភ័យ។ អម្រឹត បានកត់សម្គាល់ថា ខ្លួនក៏បានរៀបចំប្រព័ន្ធលើកទឹកចិត្តរបស់ខ្លួនឡើងវិញសម្រាប់មន្ត្រីប្រមូលបំណុល ដើម្បីទប់ស្កាត់មិនឱ្យមានការដាក់សម្ពាធមិនសមរម្យមកលើអ្នកខ្ចី។ អម្រឹត បានចាត់ទុកថា ករណីគំរាមកំហែងណាមួយ ដែលនៅតែបន្តកើតឡើង គឺបណ្តាលមកពីការមិនអនុលោមតាមគោលនយោបាយផ្ទៃក្នុងរបស់បុគ្គល និងបានបង្ហាញពីឆន្ទៈស៊ើបអង្កេតករណីបែបនេះ។ ខណៈពេលដែលការអនុវត្តការប្រមូលបំណុលបែងបង្ខំ ច្រើនតែកើតមាន នាពេលកន្លងមក ដោយសារតែការប្រជែងគ្នាក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (MFI) អម្រឹត បានកត់សម្គាល់ថា តាំងពីពេលនោះមក មន្ត្រីឥណទានបានទទួលការបណ្តុះបណ្តាលអំពីវិធីសាស្ត្រប្រមូលបំណុលប្រកបដោយក្រមសីលធម៌ ហើយគោលការណ៍ស្តីពីសិទ្ធិអតិថិជន (Customer Rights Bill) ត្រូវបានធ្វើបច្ចុប្បន្នភាព ដើម្បីពង្រឹងកិច្ចការពារអ្នកខ្ចី។

អម្រឹត បានគូសបញ្ជាក់ថា កន្លងមក មានការអនុវត្តកំណែទម្រង់ជាច្រើន ក្នុងវិស័យទាំងមូល ដូចជា ការដាក់ទណ្ឌកម្មចំពោះការប្រមូលបំណុលបែបបង្ខិតបង្ខំជាដើម។ អម្រឹតបានបញ្ជាក់ថា ខ្លួនបានរៀបចំគោលការណ៍ណែនាំច្បាស់លាស់ — អ្វីដែលត្រូវធ្វើ និងអ្វីដែលមិនត្រូវធ្វើ — សម្រាប់ការប្រមូលបំណុល ហើយបញ្ជាក់ថា អម្រឹតបានស៊ើបអង្កេតយ៉ាងសកម្មលើបណ្តឹងអំពីការប្រព្រឹត្តកំហុស។ អម្រឹតបានអះអាងថា ការស៊ើបអង្កេតរបស់ខ្លួន មិនបានរកឃើញភស្តុតាងណាមួយ ដែលបង្ហាញពីការគំរាមកំហែង ការបំភិតបំភ័យ ឬការសងសឹកឡើយ។ អម្រឹត បានអះអាងថា ខ្លួនបានផ្តល់ជម្រើសហិរញ្ញប្បទានឡើងវិញ (refinancing) ដល់ដើមបណ្តឹង ហើយបានកត់សម្គាល់ថា យោងតាមប្រវត្តិបង់ប្រាក់កន្លងមក អ្នកខ្ចីច្រើនតែបង់សងប្រាក់ទៅអម្រឹតក្រោយគេ — ពោលគឺក្រោយពីបានបង់សងអ្នកផ្តល់កម្ចីផ្សេងទៀតរួច — ដោយសារតែអម្រឹតមិនបានដាក់សម្ពាធ ដើម្បីប្រមូលបំណុល។ អម្រឹត បានបញ្ជាក់ថា ខ្លួនបានផ្អាកការទាមទារសងប្រាក់កម្ចីពីដើមបណ្តឹងតាំងពីឆ្នាំ២០២៤ មកម្ល៉េះ ដើម្បីផ្តល់ពេលវេលាឱ្យពួកគេស្តារស្ថានភាពហិរញ្ញវត្ថុឡើងវិញ។

**ទស្សនៈរបស់ LOLC**

LOLC មានចំណាប់អារម្មណ៍ក្នុងការដាក់ចេញនូវវិធានការ ដើម្បីធានាថា ការធ្លាក់ចូលក្នុងស្ថានភាពបំណុលវ័ណ្ឌករ នឹងមិនក្លាយជាបញ្ហាសម្រាប់អ្នកខ្ចីប្រាក់ឡើយ។ អ្នកជំនាញម្នាក់ត្រូវបានជួលឱ្យមកបណ្តុះបណ្តាលមន្ត្រីធនាគាររបស់ LOLC អំពីរបៀបប្រមូលកម្ចី ជាពិសេស សម្រាប់អតិថិជនដែលស្ថិតក្រោមស្ថានភាពបំណុលតានតឹង។ តាមការលើកឡើងរបស់ LOLC អាជីវកម្មរបស់ខ្លួនអាស្រ័យលើទំនុកចិត្តរវាងខ្លួន និងអ្នកខ្ចី ហើយ LOLC ក៏មានចំណាប់អារម្មណ៍ផងដែរ ក្នុងការដោះស្រាយបណ្តឹង ដើម្បីឧត្តមប្រយោជន៍របស់អ្នកខ្ចី។ ក្រុមការងារ LOLC បានពន្យល់ថា ដោយសារតែខ្លួនជឿជាក់លើបរិយាបន្ន និងការស្វែងរកវិធីដោះស្រាយបញ្ហាប្រឈ មតាមរយៈការធ្វើការរួមគ្នា LOLC ប្តេជ្ញាចិត្តក្នុងការដោះស្រាយករណីទាំងនេះ តាមរយៈការស្វែងរកដំណោះស្រាយប្រកបដោយនិរន្តរភាពរយៈពេលវែង ហើយក្នុងពេលជាមួយគ្នា នឹងខិតខំកាត់បន្ថយបញ្ហាធំៗផ្សេងទៀត ដោយទទួលស្គាល់ថា បញ្ហាបំណុលវ័ណ្ឌក គឺជាបញ្ហាដែលមានលក្ខណៈជាប្រព័ន្ធ។ LOLC បានអះអាងថា ប្តេជ្ញាចិត្តធ្វើការឆ្ពោះទៅរកការដោះស្រាយបញ្ហានេះ។

LOLC បានបង្ហាញពីឆន្ទៈសហការជាមួយដើមបណ្តឹង ដើម្បីដោះស្រាយពាក្យបណ្តឹងនេះ។ ការឆ្លើយតបរបស់ខ្លួនចំពោះកង្វល់ដែលបានលើកឡើងដោយដើមបណ្តឹង ទាក់ទងនឹងរបៀបផ្តល់កម្ចី និងប្រមូលបំណុលរបស់ខ្លួន ត្រូវបានសង្ខេបដូចខាងក្រោម។

*ការរៀបចំឥណទានឡើងវិញ*

***ដើមបណ្តឹងទី១*** - តាមការលើកឡើងរបស់ LOLC នៅខែមិថុនា ឆ្នាំ២០១៩ ដើមបណ្តឹងបានចាប់ផ្តើមខ្ចីប្រាក់តាមរយៈកម្ចីជាក្រុម និងកម្ចីគ្មានការធានា ដោយមានការបង់ការប្រាក់ជារៀងរាល់ខែ ហើយប្រាក់ដើមត្រូវបង់ជារៀងរាល់ឆ្នាំ។ LOLC បានបញ្ជាក់ថា គាត់ (ដើមបណ្តឹង) បានទទួលកម្ចីពី LOLC យកទៅធ្វើស្រូវប្រាំងនៅលើដីស្រែចំនួន ២០ ហិកតា ដែលអាចនាំមកនូវចំណូលយ៉ាងច្រើន ប្រសិនបើការប្រមូលផលស្រូវ ស្របតាមផែនការ។ ជាអកុសល ដើមបណ្តឹងបានខូចខាតដំណាំរបស់គាត់ដោយសារទឹកជំនន់។ LOLC បានបញ្ជាក់ថា ពួកគេបានព្យាយាមរៀបចំឥណទានរបស់គាត់ឡើងវិញ បន្ទាប់ពីការពិភាក្សាជាមួយគាត់ និងមិនបានអនុវត្តប្រាក់ពិន័យណាមួយឡើយ។ លើសពីនេះទៀត LOLC បានបង្ហាញថា ការធ្វើកសិកម្មនៅតំបន់មួយចំនួន ដែលអាចបង្កផលប៉ះពាល់អវិជ្ជមានដល់វិស័យជលផល ត្រូវបានហាមឃាត់ដោយរដ្ឋាភិបាលកម្ពុជា ចាប់តាំងពីដើមឆ្នាំ២០២១ ដែលបានប៉ះពាល់ដល់ដើមបណ្តឹង។

***ដើមបណ្តឹងទី២*** - យោងតាម LOLC ដើមបណ្តឹងបានចាប់ផ្តើមជាមួយកម្ចីចំនួន ៥ លានរៀល (១២៤២ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៩ ហើយនៅពេលដែលការសងប្រាក់កម្ចីមានការយឺតយ៉ាវ មន្ត្រីឥណទានបានធ្វើការជាមួយគាត់ ដើម្បីស្វែងរកជម្រើសសងប្រាក់ ដែលអាចធ្វើទៅបាន។ LOLC បានកត់សម្គាល់ថា នៅឆ្នាំ២០២៤ អត្រាការប្រាក់របស់ដើមបណ្តឹងត្រូវបានកាត់បន្ថយ ៤០ ភាគរយ ដែលធ្វើឱ្យការបង់ការប្រាក់ប្រចាំខែរបស់គាត់ ថយចុះពី

១០០,០០០ រៀល (២៥ ដុល្លារអាមេរិក) មក ៧០,០០០ រៀល (១៧ ដុល្លារអាមេរិក)។ ទោះបីជាមានការកែសម្រួលបែបនេះក៏ដោយ ដើមបណ្តឹងនៅតែបន្តជួបការលំបាកក្នុងការបង់ប្រាក់។ យោងតាម LOLC ដើម្បីជានាតម្លាភាព និងជៀសវាងការយល់ឃើញណាមួយថាមានការបង្ខិតបង្ខំ LOLC បានអញ្ជើញអ្នកខ្ចីទៅការិយាល័យឃុំ ដើម្បីប្រជុំ ដោយអនុញ្ញាតឱ្យអាជ្ញាធរឃុំធ្វើជាសាក្សីក្នុងការពិភាក្សានោះ។ ទោះបីជាតារាងពេលវេលាសងប្រាក់ ត្រូវបានព្រមព្រៀងគ្នានៅខែឧសភា ឆ្នាំ២០២៥ ក៏ដោយ អ្នកខ្ចីមិនបានធ្វើការបង់ប្រាក់នៅពេលបន្តបន្ទាប់ទេ ហើយបានដាក់ពាក្យបណ្តឹងទៅ CAO នៅខែមិថុនា ឆ្នាំ២០២៥។

### *ការវាយតម្លៃកម្ចី និងទ្រព្យធានា*

LOLC បានបញ្ជាក់ថា ដើមបណ្តឹងទាំងពីរបានទទួលកម្ចីជាក្រុមគ្មានការធានា ដែលមិនតម្រូវឱ្យមាន ឬប្រមូលយកទ្រព្យធានាឡើយ។ LOLC បានបញ្ជាក់បន្ថែមថា ខ្លួនមិនកាន់កាប់ប័ណ្ណកម្មសិទ្ធិដីធ្លីសម្រាប់អ្នកខ្ចីទាំងពីរនោះទេ ដូច្នេះ ការលក់ដីធ្លីណាមួយដែលធ្វើឡើងដោយដើមបណ្តឹង គឺមិនពាក់ព័ន្ធនឹងកម្ចីរបស់ LOLC ឡើយ។

LOLC បានគូសបញ្ជាក់ពីរបៀបផ្តល់កម្ចីរបស់ខ្លួនដែលផ្តោតលើអ្នកខ្ចី ដោយពន្យល់ថា ការវាយតម្លៃកម្ចី ត្រូវបានធ្វើឡើងដោយផ្អែកលើសមត្ថភាព ចរិតលក្ខណៈ ស្ថានភាពហិរញ្ញវត្ថុ មូលធន និងទ្រព្យធានារបស់អ្នកខ្ចី ហើយការវាយតម្លៃគ្រប់ជ្រុងជ្រោយបែបនេះ ធានាថា ការសម្រេចចិត្តផ្តល់កម្ចី ត្រូវបានធ្វើឡើង ស្របតាមស្ថានភាពហិរញ្ញវត្ថុជាក់លាក់របស់អ្នកខ្ចី។ LOLC បានបញ្ជាក់ពីវិធីសាស្ត្របត់បែនរបស់ខ្លួនចំពោះការប្រមូលកម្ចី ជាពិសេសសម្រាប់អ្នកខ្ចីដែលប្រឈមមុខនឹងការលំបាកលំបិនផ្នែកហិរញ្ញវត្ថុ។ ជាឧទាហរណ៍ ប្រសិនបើអ្នកខ្ចីមិនអាចបំពេញកាតព្វកិច្ចសងប្រាក់ពេញលេញ ប៉ុន្តែអាចធ្វើការទូទាត់មួយផ្នែកបាន LOLC នឹងទទួលយកការទូទាត់នោះ ដោយមិនប្រើប្រាស់ចំណាត់ការផ្លូវច្បាប់ឡើយ។

### *បណ្តឹងរបស់អ្នកខ្ចី និងយន្តការដោះស្រាយបណ្តឹង*

LOLC បានអះអាងថា ក្រុមប្រឹក្សាភិបាលរបស់ខ្លួន បានផ្តល់អាណត្តិឱ្យគ្រឹះស្ថាន ផ្តល់ដំណោះស្រាយដល់អ្នកខ្ចី។ LOLC និយាយថា ដូច្នេះ LOLC ប្តេជ្ញាចិត្តដោះស្រាយបញ្ហាប្រកបដោយលក្ខណៈស្ថាបនា តាមរយៈការចូលរួមជាមួយភាគីពាក់ព័ន្ធទាំងអស់ ដើម្បីស្វែងរកដំណោះស្រាយសមស្រប។ LOLC បានអះអាងថា ខ្លួនមានច្រកជាច្រើនដែលអ្នកខ្ចីអាចប្រើប្រាស់ ដើម្បីដាក់ពាក្យបណ្តឹង ដូចជា ការទំនាក់ទំនងដោយផ្ទាល់ជាមួយបុគ្គលិកសាខា ខ្សែទូរស័ព្ទទាន់ហេតុការណ៍ (hotline) របស់ LOLC ខ្សែទូរស័ព្ទទាន់ហេតុការណ៍របស់ធនាគារជាតិនៃកម្ពុជា និងមជ្ឈមណ្ឌលការពារអ្នកប្រើប្រាស់សេវាហិរញ្ញវត្ថុ ជាដើម។ LOLC ក៏បានបញ្ជាក់ផងដែរថា ខ្លួនកំពុងផ្តោតលើការកសាងទំនុកចិត្តឡើងវិញ ជាពិសេស នៅតាមតំបន់ដែលការផ្សព្វផ្សាយអំពីយន្តការដោះស្រាយបណ្តឹង (GRM) បានបរាជ័យ និងប្តេជ្ញាចិត្តពង្រឹងការចូលរួមរបស់អ្នកខ្ចី និងអភិវឌ្ឍដំណោះស្រាយរយៈពេលវែង។

LOLC បានបញ្ជាក់យ៉ាងច្បាស់ថា ខ្លួនមានប្រព័ន្ធដោះស្រាយបណ្ដឹងដែលមានរចនាសម្ព័ន្ធច្បាស់លាស់ ដែលខ្លួនជឿជាក់ថា ស្ថិតក្នុងចំណោមយន្តការដែលរឹងមាំ នៅក្នុងវិស័យនេះ។ LOLC បានអះអាងបន្ថែមថា ព័ត៌មានអំពីយន្តការដោះស្រាយបណ្ដឹងរបស់ខ្លួន ត្រូវបានផ្ដល់ជូនអ្នកខ្ចីតាមរយៈច្រកជាច្រើន ដូចជា ក្នុងឯកសារកម្ចី តារាងពេលវេលាសងប្រាក់, និងថង់ដាក់ឯកសារកម្ចីដែលបានចែកជូនអ្នកខ្ចី ដែលលេខទូរស័ព្ទទាន់ហេតុការណ៍សម្រាប់ LOLC និងខ្សែទូរស័ព្ទទាន់ហេតុការណ៍របស់សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ត្រូវបានបោះពុម្ពដោយអក្សរដិត។ តាមការលើកឡើងរបស់ LOLC ខ្សែទូរស័ព្ទទាន់ហេតុការណ៍ ត្រូវបានគ្រប់គ្រងដោយការិយាល័យកណ្ដាលរបស់ LOLC ហើយរាល់បណ្ដឹងដែលបានដាក់ស្នើ តាមរយៈច្រកនេះ ត្រូវបានត្រួតពិនិត្យដោយប្រធាននាយកប្រតិបត្តិ និងមន្ត្រីអនុលោមភាព។ LOLC ក៏បានបញ្ជាក់ឱ្យច្បាស់ផងដែរថា កិច្ចសន្យាកម្ចីរបស់ខ្លួន អនុវត្តតាមទម្រង់ស្តង់ដារ ដូចដែលបានតម្រូវក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងព័ត៌មានទំនាក់ទំនងរបស់យន្តការដោះស្រាយបណ្ដឹងផងដែរ។ ដើម្បីគាំទ្រអ្នកខ្ចីដែលមានកម្រិតអក្ខរកម្មទាប LOLC បាននិយាយថា ពួកគេបានបង្កើត "បណ្ណព័ត៌មានរូបភាព" ( illustrated "meta cards" ) ប្រហែល ២០ សន្លឹក ដែលពន្យល់ពីលក្ខខណ្ឌកម្ចី អត្រាការប្រាក់ និងនីតិវិធីដោះស្រាយបណ្ដឹង ដែលបានពន្យល់ឱ្យអ្នកខ្ចី ក្នុងអំឡុងពេលវាយតម្លៃកម្ចី និងមុនពេលការផ្ដល់កម្ចី។

ទាក់ទងនឹងពាក្យបណ្ដឹងរបស់ដើមបណ្ដឹង LOLC បានបញ្ជាក់ថា ខ្លួនមិនបានពិភាក្សាផ្លូវការណាមួយជាមួយធនាគារជាតិនៃកម្ពុជាទេ ចាប់តាំងពីពាក្យបណ្ដឹងត្រូវបានដាក់ស្នើទៅពួកគេ។ យោងតាម LOLC ការិយាល័យកណ្ដាលរបស់ខ្លួន ទើបតែបានដឹងអំពីពាក្យបណ្ដឹងទៅធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៥ ហើយខ្លួនបានបញ្ជាក់ឱ្យច្បាស់ថា ខ្លួនមិនបានដឹងថាករណីនេះត្រូវបានបញ្ជូនបន្តទៅ CAO រហូតដល់ធនាគារជាតិនៃកម្ពុជាបានទាក់ទងមក LOLC នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៥ ដើម្បីសម្របសម្រួលការសម្រុះសម្រួលជាមួយដើមបណ្ដឹង ដែលពេលនោះចំអំឡុងពេលថ្ងៃឈប់សម្រាកជាតិ។

### *ការគំរាមកំហែង និងការបំភិតបំភ័យ*

LOLC រក្សាគោលនយោបាយមិនអត់ឱនឱ្យជាដាច់ខាត ទាក់ទងនឹងការគំរាមកំហែង និងការសងសឹក ហើយបានធ្វើការស៊ើបអង្កេតផ្ទៃក្នុង លើការចោទប្រកាន់អំពីការគំរាមកំហែង និងការបំភិតបំភ័យនានា។ តាមការលើកឡើងរបស់ LOLC ការស៊ើបអង្កេតមិនបានរកឃើញភស្តុតាងណាមួយ ដែលបញ្ជាក់ថាមន្ត្រីឥណទាន បានប្រព្រឹត្តអំពើគំរាមកំហែង ឬដាក់សម្ពាធលើដើមបណ្ដឹង ឱ្យលក់ទ្រព្យសកម្មរបស់ពួកគេឡើយ។ LOLC បានបញ្ជាក់ថា ស្របតាមនីតិវិធីស្តង់ដាររបស់ខ្លួន មន្ត្រីឥណទានត្រូវចុះទៅផ្ទះរបស់អ្នកខ្ចីម្តង ឬពីរដងក្នុងមួយខែ ដើម្បីសួរនាំអំពីការសងប្រាក់កម្ចី។ ការចុះទៅផ្ទះទាំងនេះ គឺជាផ្នែកមួយនៃដំណើរការរបស់ធនាគារ ក្នុងការវាយតម្លៃអំពីមូលហេតុឫសគល់នៃការមិនបង់សងប្រាក់។

ក្នុងអំឡុងពេលចុះវាយតម្លៃពីខែកញ្ញា ដល់ខែតុលា ឆ្នាំ២០២៥ LOLC និងដើមបណ្តឹង បានព្រមព្រៀងចូលរួមក្នុងដំណើរការដោះស្រាយវិវាទ ក្រោមការសម្របសម្រួលដោយ CAO។ បន្ទាប់ពីកិច្ចប្រជុំទ្វេភាគីជាមួយភាគីទាំងពីររួចមក CAO បានកោះប្រជុំរួមលើកដំបូងរវាងភាគីទាំងមូល នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៥។ គោលបំណងគឺដើម្បីផ្តើមការពិភាក្សាអំពីបទបញ្ជាក់ផ្ទៃក្នុង ដែលគ្រប់គ្រងកិច្ចប្រជុំ និងដំណើរការនៃការចូលរួមនាពេលអនាគត។

## ៦. សេចក្តីសន្និដ្ឋាន និងជំហានបន្ទាប់

ដើមបណ្តឹង LOLC និង អម្រឹត បានព្រមព្រៀងចូលរួមក្នុងដំណើរការដោះស្រាយវិវាទ។ ដូច្នេះ CAO នឹងផ្ទេរពាក្យបណ្តឹងនេះទៅឱ្យមុខងារដោះស្រាយវិវាទរបស់ CAO ដោយអនុលោមតាមគោលនយោបាយ CAO។ CAO នឹងសម្របសម្រួលដំណើរការកិច្ចសន្ទនា រួមទាំង ការជួយភាគីទាំងពីរត្រៀមលក្ខណៈសម្រាប់កិច្ចសន្ទនា, ការព្រមព្រៀងលើបទបញ្ញាផ្ទៃក្នុង និងវិសាលភាពនៃកិច្ចសន្ទនា, និងការធ្វើការរួមគ្នាបែបសហការ ដើម្បីព្យាយាមឈានដល់ដំណោះស្រាយមួយ ចំពោះបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង និងដែលបានសង្ខេបនៅក្នុងរបាយការណ៍វាយតម្លៃនេះ។

# ឧបសម្ព័ន្ធ ក. ដំណើរការដោះស្រាយពាក្យបណ្តឹងរបស់ CAO



ដោយអនុលោមតាមគោលនយោបាយយន្តការគណនេយ្យភាពឯករាជ្យ (CAO) របស់ IFC/MIGA ជំហានខាងក្រោម ជាធម្មតាត្រូវបានអនុវត្ត ឆ្លើយតបទៅនឹងពាក្យបណ្តឹងដែលបានទទួលៈ

**ជំហានទី១ៈ** **ការទទួលស្គាល់**ការទទួលបានពាក្យបណ្តឹង។

**ជំហានទី២ៈ** **ភាពទទួលយកបាន។** ការកំណត់អំពីភាពទទួលយកបានរបស់ពាក្យបណ្តឹងសម្រាប់ការវាយតម្លៃក្រោមអាណត្តិរបស់ CAO (មិនលើសពី ១៥ ថ្ងៃនៃថ្ងៃធ្វើការ)។

**ជំហានទី៣ៈ** **ការវាយតម្លៃ។** ការវាយតម្លៃលើបញ្ហានានា និងការផ្តល់ការគាំទ្រដល់ភាគីពាក់ព័ន្ធ ក្នុងការស្វែងយល់ និងកំណត់ ថាតើពួកគេចង់បន្តដំណោះស្រាយដោយព្រមព្រៀងគ្នា តាមរយៈដំណើរការបែបសហការ ដែលកោះប្រជុំដោយមុខងារដោះស្រាយវិវាទរបស់ CAO ឬថាតើករណីនេះ គួរតែត្រូវបានទទួលបន្ទុកដោយមុខងារអនុលោមភាពរបស់ CAO ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ (due diligence) ផ្នែកបរិស្ថាន និងសង្គម របស់ IFC/MIGA។ ពេលវេលាវាយតម្លៃ អាចចំណាយពេលរហូតដល់អតិបរមា ៩០ ថ្ងៃនៃថ្ងៃធ្វើការ ដោយមានលទ្ធភាពពន្យារពេលអតិបរមា ៣០ ថ្ងៃនៃថ្ងៃធ្វើការបន្ថែម ប្រសិនបើបន្ទាប់ពីរយៈពេល ៩០ ថ្ងៃនៃថ្ងៃធ្វើការ (១) ភាគីទាំងពីរបញ្ជាក់ថា ដំណោះស្រាយលើពាក្យបណ្តឹង ទំនងជានឹងអាចកើតមាន ឬ (២) ភាគីណាមួយបង្ហាញចំណាប់អារម្មណ៍ក្នុងការដោះស្រាយវិវាទ ហើយភាគីម្ខាងទៀតអាចនឹងយល់ព្រម។

**ជំហានទី៤ៈ** **ការសម្របសម្រួលការដោះស្រាយវិវាទ។** ប្រសិនបើភាគីទាំងពីរជ្រើសរើសបន្តដំណើរការសហការ មុខងារដោះស្រាយវិវាទរបស់ CAO នឹងត្រូវចាប់ផ្តើម។ ដំណើរការដោះស្រាយវិវាទ ជាធម្មតា គឺផ្អែកលើ ឬផ្តើមឡើងដោយអនុស្សរណៈនៃការយោគយល់គ្នា និង/ឬបទបញ្ជាផ្ទៃក្នុងដែលបានព្រមព្រៀងគ្នាទៅវិញទៅមក រវាងភាគីទាំងពីរ។ ក្នុងដំណើរការនេះ អាចមានការសម្របសម្រួល/ការសម្រុះសម្រួល ការស្វែងរកការពិតរួមគ្នា ឬវិធីសាស្រ្តដោះស្រាយផ្សេងទៀតដែលបានព្រមព្រៀងគ្នា ដែលនាំទៅរកកិច្ចព្រមព្រៀងសះជា (settlement agreement) ឬគោលដៅសមស្របផ្សេងទៀត ដែលបានព្រមព្រៀងគ្នាទៅវិញទៅមក។ គោលបំណងចម្បងនៃវិធីសាស្រ្តដោះស្រាយបញ្ហាប្រភេទនេះ គឺដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង និងបញ្ហាសំខាន់ៗផ្សេងទៀត ដែលពាក់ព័ន្ធនឹងពាក្យបណ្តឹង ដែលត្រូវបានកំណត់ក្នុងអំឡុងពេលវាយតម្លៃ ឬដំណើរការដោះស្រាយវិវាទ តាមរបៀបមួយដែលភាគីរងផលប៉ះពាល់អាចទទួលយកបាន។

*ឬ*

**ការពិនិត្យវាយតម្លៃ/ការស៊ើបអង្កេតអនុលោមភាព។** ប្រសិនបើភាគីនានាជ្រើសរើសយកដំណើរការស៊ើបអង្កេត ពាក្យបណ្តឹងត្រូវបានផ្ទេរទៅមុខងារអនុលោមភាពរបស់ CAO។ ពាក្យបណ្តឹងក៏ត្រូវ

បានផ្ទេរទៅមុខងារអនុលោមភាពផងដែរ នៅពេលដែលដំណើរការដោះស្រាយវិវាទ បង្កើតឱ្យមានកិច្ចព្រមព្រៀងមួយផ្នែក ឬមិនមានកិច្ចព្រមព្រៀងទាល់តែសោះ។ សមាជិកសហគមន៍រងផលប៉ះពាល់យ៉ាងហោចណាស់ម្នាក់ ត្រូវតែផ្តល់ការយល់ព្រមច្បាស់លាស់ (explicit consent) សម្រាប់ការផ្ទេរនេះ លើកលែងតែ CAO បានដឹងអំពីការបារម្ភស្តីពីការគំរាមកំហែង និងការសងសឹក។ មុខងារអនុលោមភាពរបស់ CAO ត្រួតពិនិត្យលើអនុលោមភាពរបស់ IFC/MIGA ជាមួយនឹងគោលនយោបាយបរិស្ថាន និងសង្គម, វាយតម្លៃគ្រោះថ្នាក់ដែលពាក់ព័ន្ធ, និងផ្តល់អនុសាសន៍អំពីសកម្មភាពកែតម្រូវ (remedial actions) សមស្របណាមួយ តាមដំណើរការបីជំហាន។ ទីមួយ ការវាយតម្លៃអនុលោមភាព កំណត់ថាតើត្រូវមានការស៊ើបអង្កេតបន្ថែមដែរឬទេ។ ការវាយតម្លៃនេះអាចចំណាយពេលរហូតដល់ ៤៥ ថ្ងៃនៃថ្ងៃធ្វើការ ដោយអាចពន្យារពេល ២០ ថ្ងៃនៃថ្ងៃធ្វើការ ក្នុងកាលៈទេសៈពិសេស។ ទីពីរ ប្រសិនបើត្រូវមានការស៊ើបអង្កេត បន្ទាប់ពីការវាយតម្លៃរួច នឹងមានការស៊ើបអង្កេតលើអនុលោមភាពស៊ីជម្រៅ លើការអនុវត្តរបស់ IFC/MIGA។ នឹងមានការផ្សព្វផ្សាយជាសាធារណៈរបាយការណ៍ស៊ើបអង្កេតមួយ រួមជាមួយនឹងការឆ្លើយតបរបស់ IFC/MIGA និងផែនការសកម្មភាពមួយ ដើម្បីកែតម្រូវ (remediate) ការរកឃើញអំពីការមិនអនុលោម និងគ្រោះថ្នាក់ដែលពាក់ព័ន្ធ។ ទីបី ក្នុងករណីរកឃើញការមិនអនុលោម និងគ្រោះថ្នាក់ពាក់ព័ន្ធ CAO នឹងតាមដានលើការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃផែនការសកម្មភាពនោះ។

**ជំហានទី៥៖ ការពិនិត្យ និងការតាមដាន**

**ជំហានទី៦៖ ការបិទសំណុំរឿង**

CAO COMPLIANCE ADVISOR OMBUDSMAN

The Independent Accountability Mechanism for IFC & MIGA